មជ្ឈមណ្ឌលឯកសារកម្ពុជា

# ពីរទសវត្សរ៍នៃគណៈកម្មការស្វែងរកការពិតរបស់កម្ពុជា

*ដោយ កែវ ដាស៊ីល*

*ពីសកលវិទ្យាល័យវិសខន់ស៊ិន សហរដ្ឋអាមេរិក*

ការផ្សះផ្សារ និងការដោះស្រាយអំពើរំលោភសិទ្ធិមនុស្សទ្រង់ទ្រាយធំ ដូចជាអំពើរំលោភសិទ្ធិមនុស្សដែលមានលក្ខណៈធ្ងន់ធ្ងរដូចអំពើប្រល័យពូជសាសន៍ជាដើម តម្រូវឲ្យមានវិធានការដោះស្រាយលើសពីដំណោះស្រាយតាមផ្លូវតុលាការតែមួយមុខ ។ ជាក់ស្តែង ប្រសិនបើយើងក្រឡេកមើលដំណើរការកន្លងមករបស់តុលាការអន្តរជាតិ ជាតិ និងតុលាការចម្រុះវិញ យុត្តិធម៌តាមផ្លូវច្បាប់តែមួយមុខមិនអាចដោះស្រាយបញ្ហាជម្លោះពីអតីតកាលឲ្យបានពេញលេញទាំងស្រុងនោះទេ ។ ជាពិសេសតុលាការដែលធ្វើការកាត់ទោសតែមនុស្សមួយក្តាប់តូច ដោយទុកឲ្យជនដៃដល់រាប់រយពាន់នាក់ទៀតរួចខ្លួន ហាក់ដូចជាធ្វើឲ្យជនរងគ្រោះមិនអស់ចិត្ត ហើយពួកគេត្រូវការយន្តការយុត្តិធម៌ផ្សេងពីនេះកាន់តែខ្លាំងថែមទៀត ។ ក្នុងកាលៈទេសៈនេះ អ្នកខ្លះបានស្នើសុំឲ្យបង្កើតគណៈកម្មការស្វែងរកការពិតដោយសារគេគិតដល់តួនាទីដ៏មានតម្លៃពិតប្រាកដរបស់គណៈកម្មការនេះនៅក្នុងដំណើរការផ្សះផ្សាកម្រិតជាតិ និងកម្រិតបុគ្គល ។

កាលពីប៉ុន្មានឆ្នាំមុន ទន្ទឹមនឹងពេលដែលគេរំពឹងថានឹងមានការបង្កើតតុលាការខ្មែរក្រហម អ្នកជំនាញ និងសកម្មជនជាច្រើន បានតស៊ូមតិគាំទ្រឲ្យបង្កើតគណៈកម្មការស្វែងរកការពិតមួយនៅកម្ពុជា ។ ប៉ុន្តែអ្វីដែលអ្នកទាំងនោះមិនបានយល់ឲ្យច្បាស់នោះគឺថា កិច្ចខិតខំប្រឹងប្រែង ធ្វើការស៊ើបអង្កេត និងចងក្រងឯកសារស្តីអំពីអំពើឃោរឃៅរបស់រដ្ឋាភិបាលចាស់ ដែលកិច្ចការនេះឯងជាកិច្ចការរបស់គណៈកម្មការស្វែងរកការពិតនោះ ត្រូវបានចាប់ផ្តើមដំណើរការនៅក្នុងប្រទេសកម្ពុជាកាលពី២០ឆ្នាំមកម៉្លេះ ។ បទពិសោធន៍របស់ប្រទេសកម្ពុជាក្នុងការបង្កើតគណៈកម្មការស្វែងរកការពិតនេះ បើទោះបីជាពេលខ្លះមានការរំខាននិងមានលក្ខណៈប្លែកៗទៅតាមពេលវេលាក៏ដោយ មិនគួរត្រូវមើលរំលងដោយសហគមន៍អន្តរជាតិទេ ។ លើសពីនេះទៅទៀត បទពិសោធន៍កម្ពុជានេះ អាចជាគំរូមួយសម្រាប់ប្រទេសក្រោយជម្លោះបញ្ចប់ទៅក្នុងករណីដែលប្រទេសទាំងនេះមានទស្សនៈផ្នែកសាសនា មិនដូចគ្នាទៅនឹងខាងបស្ចិមប្រទេស ។ សម្រាប់ប្រទេសទាំងនេះ ទស្សនៈអំពីការសារភាព និងការអត់ឱនទោស មានការខុសប្លែក

គ្នាយ៉ាងខ្លាំង ហើយភាពខុសប្លែកគ្នាទាំងនេះ គួរតែត្រូវយកមកពិចារណានៅពេលសម្រេចលើបែបបទ និងតួនាទីរបស់គណៈកម្មការស្វែងរកការពិត ។

បើពិនិត្យមើលអំពីដំណើរដ៏វែងឆ្ងាយរបស់កម្ពុជា នៅក្នុងការលាតត្រដាង និង កត់ត្រានូវអំពើឃោរឃៅរបស់របបខ្មែរក្រហម យើងបានរកឃើញនូវវិធានការណ៍ច្បាស់លាស់ និងខុសប្លែកៗគ្នាជាច្រើន ។ វិធានការណ៍ទីមួយ គឺការប្រមូលព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់អំពីការខូចខាត និងការស្លាប់របស់ជនរងគ្រោះ ដំណាលគ្នានឹងការប្រមូលហត្ថលេខាពីមនុស្សជាងមួយលាននាក់ ។ ទាំងនេះគឺមាននៅក្នុងឯកសារញត្តិរណសិរ្សកាលពីឆ្នាំ១៩៨២ ដែលញត្តិនេះបានស្នើសុំជំនួយរបស់សហគមន៍អន្តរជាតិឲ្យកាត់ទោសឧក្រិដ្ឋកម្មរបស់របបខ្មែរក្រហម ។ វិធានការណ៍ដទៃទៀតនៅក្នុងទសវត្សរ៍ឆ្នាំ៨០ រួមមានការស្ថាបនាបូជនីយ៍ដ្ឋានចំនួន៨៨នៅទូទាំងប្រទេស និងការកសាងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងនៅរាជធានីភ្នំពេញ ។ ច្បាប់ស្តីអំពីយុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជាដែលត្រូវបានអនុម័តកាលពីឆ្នាំ១៩៩៤ ក៏ដូចជាកម្មវិធីអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាមានតួនាទីដ៏សំខាន់ក្នុងការលើកកម្ពស់ដល់ការស៊ើបអង្កេត និងការកត់ត្រាឯកសារឧក្រិដ្ឋកម្មខ្មែរក្រហម ។ កើតចេញពីកិច្ចខិតខំប្រឹងប្រែងទាំងពីរនេះ មជ្ឈមណ្ឌលស្រាវជ្រាវមួយត្រូវបានបង្កើតឡើង ហើយគោលបំណងសំខាន់បំផុតរបស់មជ្ឈមណ្ឌលនេះគឺកត់ត្រា និងស្រាវជ្រាវអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយមានជំនួយពីសំណាក់អ្នកជំនាញអន្តរជាតិ និងការគាំទ្រពីសំណាក់ប្រជាជនសាមញ្ញដ៏ច្រើនលើសលប់កាលពី១០ឆ្នាំកន្លងទៅនេះ មជ្ឈមណ្ឌលស្រាវជ្រាវនេះបានធ្វើជាផែនទីរណ្តៅសាកសពដែលនៅក្នុងផែនទីនេះមានរណ្តៅចំនួន១៩,០០០កន្លែង បោះពុម្ពផ្សាយសៀវភៅច្រើនជាង២០ក្បាល និងបោះពុម្ពទស្សនាវដ្តីដែលចុះផ្សាយរៀងរាល់ខែ ព្រមទាំងបានលើកកម្ពស់តួនាទីរបស់ជនរងគ្រោះ និងអ្នករស់រានមានជីវិតក្នុងដំណើរការផ្សះផ្សាផ្លូវចិត្ត ។ កិច្ចការសំខាន់បំផុតកន្លងមកនេះ គឺជាគម្រោងសហប្រតិបត្តិការណ៍ជាមួយនឹងក្រសួងអប់រំ ដើម្បីការបង្រៀនអំពីអំពើប្រល័យពូជសាសន៍ទូទាំងប្រទេស ។

គណៈកម្មការស្វែងរកការពិតរបស់កម្ពុជា ឬហៅម្យ៉ាងទៀតថាគណៈកម្មការស្វែងរកការពិតតាមបែបកម្ពុជាបានផ្តល់នូវទស្សនៈមួយចំនួនចំពោះយន្តការយុត្តិធម៌មួយនេះ ។ ដំបូងគេបង្អស់ គោលបំណងរបស់គណៈកម្មការស្វែងរកការពិត មិនចាំបាច់តែត្រូវធ្វើឡើងនៅក្នុងទម្រង់ជាគណៈកម្មការនោះទេ ។ ញត្តិ បូជនីយដ្ឋាន សារមន្ទីរ មជ្ឈមណ្ឌលស្រាវជ្រាវ និងការអប់រំអំពីអំពើប្រល័យពូជសាសន៍ប្រហែលអាចជាវិធានការណ៍សមស្របទៅនឹងស្ថានភាពជាក់ស្តែងជាងគណៈកម្មការនោះទៀតផង ។ ទីពីរ ទឹកប្រាក់ចំនួនរាប់លានដុល្លារ និងឆន្ទៈនយោបាយដ៏រឹងមាំ គឺមិនចាំបាច់តម្រូវឲ្យមានជាមុននោះទេ ។ ការផ្តួចផ្តើមគំនិតពីសំណាក់ប្រជាជនថ្នាក់មូលដ្ឋាន និងមនសិកាខិតខំប្រឹងប្រែង អាចជួយកាត់បន្ថយការ

ចំណាយលើផ្នែកនយោបាយនិងសេដ្ឋកិច្ច ។ ទីបី ការអប់រំទូទាំងប្រទេសស្តីអំពីអំពើប្រល័យពូជសាសន៍កាលពីអតីតកាល គួរតែជាធាតុដ៏សំខាន់មួយឈានទៅរកការសម្រេចបាននូវគោលបំណងសំខាន់របស់គណៈកម្មការស្វែងរកការពិត ពោលគឺការផ្សះផ្សា និងការធូរស្បើយផ្លូវចិត្ត ។ ដូចដែលយើងបានឃើញនៅក្នុងករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក្នុងរយៈកាលពីរទសវត្សរ៍កន្លងមក វាតម្រូវឲ្យមានការយល់ដឹងកាន់តែទូលំទូលាយជាងនេះទៅទៀត និងរបៀបក្នុងការបង្កើតគណៈកម្មការស្វែងរកការពិតនេះ ដែលការនេះតម្រូវឲ្យពិនិត្យមើលអំពីភាពខុសគ្នារបស់ប្រទេសនីមួយៗ និងគោលដៅសំខាន់របស់គណៈកម្មការស្វែងរកការពិត ព្រមទាំងវិធីសាស្ត្រផ្សេងៗដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ។